# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងបបែល

## រយៈពេល ៣ ឆ្នាំ

## (២០១៨ ដល់២០២០)

សហគមន៍នេសាទ : បឹងបបែល

ភូមិ : កងមាស

ភូមិ : ត្នោតជុំ១

ភូមិ : ត្នោតជុំ២

ភូមិ : ត្នោតជុំ៣

ភូមិ : ត្នោតជុំ៤

ភូមិ : បន្ទាយចាស់

ភូមិ : ភូមិថ្មី

ភូមិ : ព្នៅ

ភូមិ : ព្រៃកក្រោល

ឃុំ : ឃុំត្នោតជុំ

ស្រុក : បារាយណ៍

ខេត្ត : កំពង់ធំ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងបបែល
# រយៈពេល ៣ ឆ្នាំ
# (២០១៨ ដល់២០២០)

ឈ្មោះសហគមន៍នេសាទ : **សហគមន៍នេសាទ បឹងបបែល**

ភូមិ : កងមាស, ត្នោតជុំ១, ត្នោតជុំ២, ត្នោតជុំ៣, ត្នោតជុំ៤ បន្ទាយចាស់, ភូមិថ្មី, ភូមិត្នៅ និងភូមិព្រៃកក្រោល

ឃុំ : ឃុំត្នោតជុំ

ស្រុក : បារាយណ៍

ខេត្ត : កំពង់ធំ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

១ ស្ថានភាពទូទៅ

២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ១៩០៨ គ្រួសារ ប្រជាជន ៩២១៦ នាក់ ស្រី ៤៦៨០ នាក់ ។ ក្នុងនោះមានជនជាតិខ្មែរចំនួន ១០០ភាគរយ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៩៧ នាក់ ពោះម៉ាយ ៧៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២០៨ នាក់ ស្រី ១១០ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៦៥ នាក់ ស្រី ៣៧នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន ១៥នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់ព្រះពុទ្ធសាសនា ១០០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមាន ៤៦៦នាក់ ស្រី ៣២៦នាក់ ។

ខ-មុខរបរ

ចំនួនរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមាន:

- នេសាទត្រីចំនួន ៥០%គ្រួសារសរុប
- ធ្វើស្រែចំនួន ៩០%នៃគ្រួសារសរុប អត់ធ្វើស្រែ ១០%
- ដាំបន្លែចំនួន ៣០ គ្រួសារ (៣គ្រួសារ ក្នុង ១ភូមិ)
- ចិញ្ចឹមត្រី ០២គ្រួសារ
- ជាងផ្ទះ ចំនួន ១៣ នាក់
- ចំនួនអ្នកលក់ដូរ ៥៦ គ្រួសារ
- ចំនួនអ្នករត់ម៉ូតូឌុប ៩ គ្រួសារ
- ចំនួនអ្នកឡើងត្នោត ៣១នាក់
- ចំនួនអ្នកស៊ីឈ្នួលគេ (កម្មករសំណង់) ៨០ភាគរយ
- គ្រូបង្រៀន៣៣នាក់(ស្ត្រី ១៦នាក់)
- ចំនួនមណ្ឌលសុខភាព ១កន្លែង
- ចំនួនជាងកាត់ដេរសំលៀកបំពាក់ ១២.នាក់
- ចំនួនកម្មកររោងចក្រ ១០០០.នាក់
- ម៉ាស៊ីនកិនស្រូវ ៥៩ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក. ទីតាំង

កន្លែងនេសាទសហគមន៍នេសាទបឹងបបែលដែននេសាទទឹកសាបមានលក្ខណៈជាបឹងជាកន្លែងនេសាទសាធារណៈរបស់រដ្ឋ។ កន្លែងសហគមន៍នេសាទនេះមានទំហំ ២០៣.៥០ ហិចតា និងមានកំណត់និយាមកា ដូចមានចែងក្នុងកិច្ចព្រមព្រៀង។

សហគមន៍នេសាទបឹងបបែលមានព្រំប្រទល់ ៖

- ខាងជើងទល់នឹង ផ្លូវដៃអណ្តូង (ចំងាយ២០ម៉ែត្រពីមាត់បឹងបបែល)
- ខាងត្បូងទល់នឹង វាលឡាតក្តុង (ចំងាយ២០ម៉ែត្រពីមាត់បឹងបបែល)
- ខាងកើតទល់នឹង ដៃអាវកោះ (ចំងាយ២០ម៉ែត្រពីមាត់បឹងបបែល)
- ខាងលិចទល់នឹង អូរដៃដំរីជាន់ (ចំងាយ២០ម៉ែត្រពីមាត់បឹងបបែល)

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍បឹងបបែលមាន បឹងចំនួន ០១ និងអូរដៃដំរីជាន់ ចំនួន ០១។

- បឹងបបែលមានទំហំ ២០៣.៣៦ ហិចតា ការនេសាទត្រី ពេញមួយឆ្នាំ
- ព្រែកដៃដំរីជាន់ប្រវែងប្រហែល ៣០០ម៉ែត្រ ការនេសាទត្រី ៨ខែ(ខែ០៨ ដល់ខែ ០៣)

គ. ព្រៃលិចទឹក

- ដីទំនាបលិចទឹក និងព្រៃលិចទឹកទំហំសរុប ២២ហិចតា

ឃ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស គឺមាន ១កន្លែង

- អន្លង់នៅទល់មុខជ្រោយអ្នកតា ដែលមានទំហំ ១០.៦ ហិចតា ដែលមានបណ្តោយ ៤១៤ និងទទឹង ២៥៦ ម៉ែ្រត។

ង. ធនធានជលផល

- ប្រភេទត្រីមាន៖ ត្រីឆ្លាត ត្រីឆ្លាំង ត្រីក្រម៉ម ត្រីអណ្តែង ត្រីចង្វា ត្រីកំភ្លាញ ត្រីឆ្ដូញ ត្រីក្រាញ់ ត្រីខ្មាន់ ត្រីឆ្ពិន ត្រីប្រកែង ត្រីកន្ធ្រប់ ត្រីដំរី ត្រីកញ្ចាញ់ច្រាស់ ត្រីកញ្ជ្រូក ត្រីខ្សាច់ ត្រីកាហែរ ត្រីកំភ្លៀវ ត្រីលិញ ត្រីត្រនេល ត្រីប្រលឹង ត្រីព្រលូង ត្រីស្លឹកឫស្សី និងត្រីខ្ទីង ត្រីសណ្តាយ ត្រីក្រោស ត្រីរៀល ត្រីរ៉ស់ ត្រីឆ្តោរ ត្រីកញ្ចុះ ត្រីផ្ទោង ត្រីគល់រាំង ត្រីក្រាយ ត្រីឆ្លាត ត្រីក្រាញ ត្រីអណ្តែញ ត្រីផ្ទក ត្រីកេស ត្រីកំប្លិញ ត្រីកន្ធរ។
- ប្រភេទដែលសំបូរ៖ ត្រីក្រោស ត្រីក្រាញ់ ត្រីរៀល ត្រីអណ្តែង ត្រីឆ្ពិន ត្រីកំប្លិញ ត្រីកន្ធ្រប ត្រីឆ្ដូញ...
- ត្រីកំរ៖ កញ្ជូន គោរាំង ក្រាយ ក្តី កាហែ ដំរី ក្រុំ ត្រីខ្លា។
- សត្វទឹក៖ ក្អែក ក្រពើ ពស់ អន្សង ពស់ កន្ធាយ មាន់ទឹក ក្តាម ខ្យង ក្រុំ លៀស កង្កែប គីង្គក់ និងឆ្លើង។
- សត្វកម្រ៖ ប្រវឹក ក្រពើ អណ្តើក កន្ធាយ ត្រដក់ ក្អែកទឹក។
- ប្រភេទសត្វស្លាបមាន៖ កុកស ប្រវឹក ខ្លុំ ទាព្រៃ រនាលខ្យង ក្រសារ ត្រដក់ ក្អែកទឹក ស្មោញ អែរអូត កុកក្រកមាន់ទឹក ទោល ទោម។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិមាន៖ ដើមរាំង ភ្នំភ្លែង អញ្ចាញ ត្រស់ សណ្តាន់ បបួយ តាអូរ ត្រឡែកខ្ទុំ ទៀនព្រៃ ថ្លើមអណ្តើក ខ្នាយមាន់ តាសែង ញរ ប្រផេញ វល្លិ៍ប្រេង ឈ្លើយ សណ្តាន់ ល្អក់ វល្លិ៍ដូងព្រះវល្លិ៍តាអើក កំប្លោក កំពឹងពួយ ចក ស្មៅ ត្រកួន កញ្ឆែត ស្លាបប្រវា សារាយ ក្រចាប់ ព្រលិត រំចង់ ម្តេញ ញរ។
- កម្រ៖ ដើមតាអូរ ខ្ទុំ តាសែង

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

មុខរបរនេសាទក៏ជារបរមួយយ៉ាងសំខាន់របស់សមាជិកសហគមន៍ និងអ្នកនេសាទដែលរស់នៅភូមិជិតខាង និងអ្នកក្រៅតំបន់ដែលប្រើឧបករណ៍ និងមធ្យោបាយនេសាទដូចមានខាងក្រោមនេះ៖

- អ្នកនេសាទចូលនេសាទប្រចាំឆ្នាំ ៥០០ នាក់ ស្ត្រី ១០០នាក់
- អ្នកមិនមែនសមាជិកសហគមន៍ ២០០នាក់ ស្ត្រី ១០០នាក់
- អ្នកជាសមាជិកសហគមន៍ ៤០០នាក់ ស្ត្រី ១០០នាក់

### ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទុកកាណូតរបស់សមាជិកសហគមន៍

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ស្រោម | ១០ | ១៦០០ម(ក្រឡា ២.៥ហ៊ុន-៧ហ៊ុន) | ពេញមួយឆ្នាំ |
| អួន | វង់(១វង់ ៨០ម) | ៣០ | ២៤០០ម(១.៥ហ៊ុនឡើង) | ខែ ២ ដល់ ខែ ៥ |
| សន្ទូចរនង | សាង (១ស=២០០ផ) | ១០០ | ២០០០០ផ្លែ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១០០ | - ក្រឡា=២.៥ សមឡើង<br>- ៩ហាត់ | ខែ០២ ទៅ ខែ ០៧ |
| បបក់ | ១ដើម | ១៣ | - ផ្លែលេខ ១២-១៣ | ខែ១០-ខែ ០៧ |
| លាន់ | គ្រឿង | ៣០០(២០០នាក់) | ៣០០០០ | ពេញមួយឆ្នាំ |
| បង្កៃ | ផ្លែ | ១៥០ (៣នx៥០ផ) | ផ្លែលេខ ១២-១៣ | ខែ ២ -ខែ ៥ |
| លប | គ្រឿង | ៤០០ | ៤០០លប | ពេញមួយឆ្នាំ |
| ប៉ោងអន្ទង់ | គ្រឿង | ៣០០ | មិនមានទំហំ | ខែ ២ -ខែ ៥ |
| កញ្ជ្រោងអូសលាស | គ្រឿង | ៥ | មិនមានទំហំ | ខែ ២ -ខែ ៥ |
| ចរ | វង់ | ៥ | ក្រឡា ៤ហ៊ុន<br>ប្រវែង ៣ម | ខែប្រាំង |
| ឆ្នុកបុរាណ | គ្រឿង | ១០ | ក្រឡា ៣.៥ហ៊ុន<br>ទំហំ ៤មx៤ម | ខែប្រាំង |
| ឆក់ | គ្រឿង | ៥០ | | ពេញមួយឆ្នាំ |
| ស្នៀមុង | គ្រឿង | ៥ | | ពេញមួយឆ្នាំ |
| របាំងសាច់អួន | គ្រឿង | ១០ | ក្រឡា ២.៥ហ៊ុនឡើង | ពេញមួយឆ្នាំ |
| លបប្រើស ១០០ | គ្រឿង | ១០០ | | ពេញមួយឆ្នាំ |

| | | | | |
|---|---|---|---|---|
| ទូត្រីឆ្កួញ | គ្រឿង | ៣០០ | | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| កាណូត | ២០ គ្រឿង | ២០០គក្រ | ៦-១៦ សេះ |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ដៃ(១ដ=៥០ម) | ៤៣៦(២១៨នx២ដ) | -ក្រឡា=២.៥-៦ហ៊ុន<br>-សំរុង=៥ម<br>-ប្រវែង=៣០ម | ខែ១១ ទៅ ខែ ១២ |
| សន្ទូចរនង | សាង(១ស=១០០ផ) | (៥នx១សាងx១០០) | -ផ្លែលេខ=១៣-១៦ | ខែ០១ ទៅ ខែ ១២ |
| សំណាញ់ | ១ន=១វង់ | ៣០(៣០នx១វង់) | - ក្រឡា=១.៥ សម<br>- សំរុង=៥ម | ខែ០២ ទៅ ខែ ០៧ |
| អួនព្រយុង | វង់(១វ=៣០ម) | ៥០០(១០នx៥០ម) | -ក្រឡា=៣ ហ៊ុន<br>-សំរុង=៤ម<br>-ប្រវែង=៣០ម | ខែ០៣ ទៅ ខែ ០៦ |
| បបក់ | ១ន=១ដើម | ១៣(១៣នx១ដ) | - ផ្លែលេខ ១២-១៣ | ខែ០៧ ខែ ១០ |
| លាន់ | ១នាក់=១០ | ២០(២នx១០) | ២០(២នាក់x១០) | ខែ០៧ ខែ ១០ |
| បង្កៃ | ផ្លែ | ១៥០(៣នx៥០ផ) | ផ្លែលេខ ១២-១៣ | ខែ០២ ខែ ០៥ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| ទូកអុំ ឬចែវ | ៣៥ គ្រឿង | ២០០-៤០០គក្រ | គ្មាន |
| កាណូត | ៥ គ្រឿង | ២០០-២៥០គក្រ | ៦-១៨ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ស្រោម | ១០ | ១៦០០ម(ក្រឡា ២.៥ហ៊ុន- | ពេញមួយឆ្នាំ |

| | | | | |
|---|---|---|---|---|
| | | | ៧ហ៊ុន) | |
| អួន | វង់(១វង់ ៨០ម) | ៣០ | ២៤០០ម(១.៥ហ៊ុនឡើង) | ខែ ២ ដល់ ខែ ៥ |
| សន្ទូចរនង | សាង (១ស=២០០ផ) | ១០០ | ២០០០០ផ្លែ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១០០ | - ក្រឡា=២.៥ សមឡើង<br>- ៩ហាត់ | ខែ០២ ទៅ ខែ ០៧ |
| បបក់ | ១ដើម | ១៣ | - ផ្លែលេខ ១២-១៣ | ខែ១០-ខែ ០៧ |
| លាន់ | គ្រឿង | ៣០០(២០០នាក់) | ៣០០០០ | ពេញមួយឆ្នាំ |
| បង្កៃ | ផ្លែ | ១៥០(៣នx៥០ផ) | ផ្លែលេខ ១២-១៣ | ខែ ២ -ខែ ៥ |
| លប | គ្រឿង | ៤០០ | ៤០០លប | ពេញមួយឆ្នាំ |
| ប៉ោងអន្ទង់ | គ្រឿង | ៣០០ | | ខែ ២ -ខែ ៥ |
| កាព្រៀងរាវលាស | គ្រឿង | ៥ | | ខែ ២ -ខែ ៥ |
| ចរ | វង់ | ៥ | ក្រឡា ៤ហ៊ុន<br>ប្រវែង ៣ម | ខែប្រាំង |
| ឆ្នុកបុរាណ | គ្រឿង | ១០ | ក្រឡា ៣.៥ហ៊ុន<br>ទំហំ ៤មx៤ម | ខែប្រាំង |
| ឆក់ | គ្រឿង | ៥០ | | ពេញមួយឆ្នាំ |
| ស្បៃមុង | គ្រឿង | ៥ | | ពេញមួយឆ្នាំ |
| របាំងសាច់អួន | គ្រឿង | ១០ | ក្រឡា ២.៥ហ៊ុនឡើង | ពេញមួយឆ្នាំ |
| លបប្រើស ១០០ | គ្រឿង | ១០០ | | ពេញមួយឆ្នាំ |
| ទ្រូត្រីឆ្លូញ | គ្រឿង | ៣០០ | | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| កាណូត | ៣០ គ្រឿង | ៨០០-១៥០០គក្រ | ៦-១៨ សេះ |

គ. ប៉ាន់ប្រម៉ាណផលចាប់នេសាទប្រចាំឆ្នាំ

| ប្រភេទលផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ២គ.ក | ៣គ.ក | ៥ គ.ក |

| ក្តាម ខ្យង, លៀស | ១ គ.ក | ២គ.ក | ៣ គ.ក |
|---|---|---|---|

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទបឹងបបែលមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើការនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងបំរុងទំនាបលិចទឹកក្នុងនាទីព្រៃលិចទឹក។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាសហគមន៍ប្រកបដោយសមធម៌។
- ដើម្បីធ្វើអោយប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចម្រុះ ដោយមានការចូលរួម។
- ដើម្បីអោយប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងស្របតាមលក្ខន្តិកៈនៃសហគមន៍នេសាទបឹងបបែលៈ

| ឈ្មោះ/ទីតាំង/កន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតអោយប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| - បឹងបបែល | ខែ១-៥ និង ខែ ១០-១២ | អួន | -ក្រឡាចាប់ពី២.០០ស.ម<br>-ប្រវែង=៥០ម | ៥វង់/ថ្ងៃ | |
| | ខែ១-៥ និង ខែ ១០-១២ | សំណាញ់ | -ក្រឡាចាប់ពី២.០០ស.ម<br>-ប្រវែង=៦ម | ១០វង់/ថ្ងៃ | |
| | ខែ១-៥ និង ខែ ១០-១២ | បបក់ | | មិនកំណត់ | |
| | ខែ១-៥ និង ខែ ១០-១២ | លាន់ | | ១០០លាន់ | |

| | | | | | |
|---|---|---|---|---|---|
| | ខែ១-៥ និង ខែ ១០-១២ | បង្កៃ | ផ្លែលេខ: ១២-១៤ | មិនកំណត់ | |
| | ខែ១-៥ និង ខែ ១០-១២ | លប | រួមផ្សំរបាំងព្រួលមិនអោយលើសពី៥០ម៉ែត្រ | ៥០/ថ្ងៃ | |
| | ខែ១-៥ និង ខែ ១០-១២ | ចរ | មិនកំណត់ | ១០វង់/ថ្ងៃ | |
| | ខែ១-៥ និង ខែ ១០-១២ | ទ្រូត្រីឆ្លូញ | | ៥០លប/ថ្ងៃ | |
| | ខែ១-៥ និង ខែ ១០-១២ | មង | ២,៥សង់ទីម៉ែត្រឡើង (តែត្រូវតូចជាង១៥សង់ទីម៉ែត្រ) | ១០ស្រោម/ថ្ងៃ | |

ប្រភេទឧបករណ៍នេសាទហាមឃាត់មិនអនុញ្ញាតិអោយប្រើប្រាស់

1. របាំងសាច់អួន
2. ឧបករណ៍ឆក់
3. របាំស្បៃមុង
4. សម្រាស់
5. លបប្រើស១០០
6. ឧបករណ៍ផ្សេងៗទៀតដែលច្បាប់ហាមឃាត់

**គ.២ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

**គ.២.១ អភិរក្សត្រីពូជ**

ការរៀបចំកន្លែងអភិរក្ស និងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់មុខជ្រោយអ្នកតា | ១០.៦ | -អន្លង់ត្រីពូជ សត្វទឹក សត្វស្លាប និងជីវៈចម្រុះ | -បោះបង្គោលព្រំប្រទល់ | ២០១៧ | ២០១៨ | សុំជំនួយ |
| | | | -ដាក់ស្លាកសញ្ញាហាមឃាត់ ៤ស្លាក | ២០១៧ | ២០១៨ | សុំជំនួយ |
| | | | -ដាក់ជម្រកសប្បនិម្មិត្ត | ២០១៨ | ២០២០ | សុំជំនួយ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | -លែងត្រី | ២០១៨ | ២០២០ | សុំជំនួយ |
| | | | -សង់រោងយាមល្បាត | ២០១៨ | ២០២០ | សុំជំនួយ |

គ.២.៣ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

គោលបំណង

- ងាយស្រួលក្នុងការគ្រប់គ្រង និងសហគមន៍ត្រូវតែមានព្រំប្រទល់ច្បាស់លាស់
- កាត់បន្ថយទំនាស់នេសាទនៅក្នុងតំបន់គ្រប់គ្រង
- ផ្សព្វផ្សាយដល់សាធារណៈជនទូទៅអោយបានដឹងពីទំហំ និងព្រំប្រទល់កន្លែងនេសាទដែលគ្រប់ដោយសហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ១៥៦ បង្គោល | តាមចំណុចនិយាមកាលើផែនទីសហគមន៍ | -គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរឃុំ | ២០១៨ | ២០២០ | សុំជំនួយ |
| ដាក់ស្លាក | ៤ស្លាកតាមព្រំ | -គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរឃុំ | ២០១៨ | ២០២០ | សុំជំនួយ |

គ.២.៤ ផែនការលើកភ្លឺព្រំប្រទល់សហគមន៍

គោលបំណង៖

- ទប់ និងរក្សាទឹកក្នុងបឹងបានច្រើនធ្វើអោយជីវចម្រុះក្នុងបឹងងាយស្រួលក្នុងការរស់នៅ
- ងាយស្រួលក្នុងការធ្វើដំណើរ និងចុះបង្ក្រាបបទល្មើសនេសាទនៅបរិវេណបឹង

| ប្រវែងភ្លឺត្រូវលើក | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ប្រវែង៧០០០ម ១ខ្នងភ្លឺ ជើងក្រោម២ម ជម្រៅ ០.៥ម | ជុំវិញមាត់បឹង | -គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរឃុំ | ២០១៨ | ២០២០ | សុំជំនួយ ៣៥,០០០,០០០ |

គ.២.៥ ផែនការគ្រប់គ្រងព្រៃលិចទឹក

គោលបំណង

- ថែរក្សា ការពារ និងប្រើប្រាស់ព្រៃលិចអោយគង់វង្សយូរអង្វែង

- ទប់ស្កាត់ការរុករានទន្រ្ទានព្រៃលិចទឹកពីជនល្មើស

- បង្កើន និងរក្សាទុកជាជំរកត្រី និងសត្វពងកូន រក្សាលំនឹងបរិស្ថាន បង្កើនទិន្នផលត្រីដើម្បីលើកកំពស់ជីវភាពរស់នៅ។

**គ.២.៦ ផែនការដាំព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមានក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ជុំវិញបឹងបបែល | ៣ ហត | - កូនរាំង ត្រស់ រំដេញ តាសែង និងអញ្ចាញ | -កំណត់ទីតាំង<br>-បណ្តុះកូនឈើ<br>- អនុវត្តពិធីដាំកូនឈើ<br>-ថែរក្សា | ២០១៨ | ២០២០ | |

**គ.២.៧ ផែនការអភិវឌ្ឍន៍អភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព**

ផែនការចិញ្ចឹមមាន់ត្រូវអភិវឌ្ឍន៍ដូចខាងក្រោមៈ

| ប្រភេទមុខរបរ | ចំនួន | សកម្មភាព | ខែ/ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | ប្រមូលផល |
| ដាំបន្លែ | ២០គ្រួសារ | • កំណត់ទីកន្លែងដែលត្រូវដាំ<br>• ផ្តល់បច្ចេកទេសដាំបន្លែ និងសម្ភារៈ<br>• ចែកគ្រាប់ពូជ<br>• អនុវត្តការដាំ<br>• ថែទាំ | ២០១៨ | ២០២០ |
| ចិញ្ចឹមមាន់ | ៥០គ្រួសារ | • ធ្វើទ្រុង<br>• ផ្តល់បច្ចេកទេស និងសម្ភារៈ<br>• ផ្តល់ពូជមាន់<br>• អនុវត្តការចិញ្ចឹមមាន់<br>• ថែទាំ | ២០១៨ | ២០២០ |
| ចិញ្ចឹមត្រី | ១០គ្រួសារ | • បណ្តុះបណ្តាលបច្ចេកទេស<br>• រៀបចំស្រះ ឬបែរ<br>• អនុវត្តការចិញ្ចឹម<br>• តាមដាន និងថែទាំ | ២០១៨ | ២០២០ |

គ.២.៨ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| ពង្រឹងក្រុមសន្សំ និងប្រាក់កម្ចី | - ផ្សព្វផ្សាយផលប្រយោជន៍ការសន្សំ<br>- ចងក្រងក្រុម បង្កើតគោលការណ៍<br>- ការសន្សំប្រាក់ ការធ្វើឥណទាន<br>- ការផ្តល់ទុន<br>- តាមដានត្រួតពិនិត្យ | ២០១៧ | ២០១៩ | ស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំ |
| ពង្រឹងបណ្តាញសហគមន៍នេសាទ | - ជ្រើសរើសក្រុមបណ្តាញ(ស្ម័គ្រចិត្ត)<br>- បណ្តុះបណ្តាលតួនាទីតួនាទីក្រុមបណ្តាញ<br>- រៀបចំផែនការប្រជុំរបស់ក្រុមបណ្តាញ | ២០១៧ | ២០១៩ | ស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំ |
| រៀបចំការល្បាត និងឃ្លាំមើលដែននេសាទ | - រៀបចំក្រុមល្បាតនៅតាមភូមិនីមួយៗ<br>- ធ្វើផែនការល្បាត | ២០១៧ | ២០១៩ | ស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំ |

គ.២.៩ ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

គោលបំណង

- បង្កើនសមត្ថភាពគណៈកម្មការសហគមន៍
- ពង្រឹងសហគមន៍នេសាទ
- មានសាមគ្គីភាព និងទំនាក់ទំនងល្អ

| ប្រភេទវគ្គបណ្តុះបណ្តាល | អ្នកទទួលខុសត្រូវ | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| តួនាទី និងភារកិច្ចរបស់គណៈកម្មការសហគមន៍ | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| ច្បាប់ស្តីពីជលផល | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| ជំនាញនៃការទំនាក់ទំនង និងភាពជាអ្នកដឹកនាំ | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| វិធីសាស្ត្រស្វែងថវិកា និងការសរសេរគម្រោងសំណើសុំថវិកា និងកិច្ចការរដ្ឋបាល | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| បង្កើនការយល់ដឹងស្តីអំពីច្បាប់ជលផល | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៩ | ២០២៣ | ៣ថ្ងៃ |
| វិធីសាស្ត្រដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៩ | ២០២៣ | ៣ថ្ងៃ |

| | | | | |
|---|---|---|---|---|
| ជំនាញក្នុងការសម្របសម្រួល និងការតៀងគរអោយមានការចូលរួមក្នុងសហគមន៍ | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| ការគ្រប់គ្រងធនធានធម្មជាតិ | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |
| រៀបចំទស្សនៈកិច្ចសិក្សា | អាជ្ញាធរឃុំ និងគណៈកម្មការ | ២០១៨ | ២០២៣ | ៣ថ្ងៃ |

គ.២.១០ ផែនការផ្សព្វផ្សាយ បណ្តុះបណ្តាលបង្កើនការយល់ដឹង

| ផែនការ | សកម្មភាព | ថ្ងៃខែចាប់ផ្តើម | ថ្ងៃខែបញ្ចប់ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផែនទី កំណត់ព្រំប្រទល់កន្លែងនេសាទ | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផែនការគ្រប់គ្រងកន្លែងនេសាទ | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ច្បាប់ជលផល | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ការគ្រប់គ្រងព្រៃលិចទឹក | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុល | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ការគ្រប់គ្រងកន្លែងអភិរក្ស | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផ្សព្វផ្សាយគោលការណ៍សន្សំ | ២០១៨ | ២០២០ | អាជ្ញាធរ និងគណៈកម្មការ | ស្នើសុំអង្គការ, ឃុំ, ជលផល |

គ.២.១១ ផែនការសង់ផាងយាមសហគមន៍

| ចំនួន | ទីតាំង | ទំហំ | សម្ភារៈ | ថវិកា | សកម្មភាព |
|---|---|---|---|---|---|
| ១ | បឹងបបែល | ៤ម x ៥ម | ឈើ ប្រក់ស័ង្កសី ដែកគោល ពោង ឬធុងជ័រ ឬស្សី | ៣៥០០ដុល្លា | ស្វែងរកថវិកាគាំទ្រ ទិញសម្ភារៈ សាងសង់ |

គ.២.១២ ផែនការល្បាតក្នុងកន្លែងនេសាទសហគមន៍

| ឈ្មោះសកម្មភាព | ចាប់ផ្តើម | បញ្ចប់ | សម្ភារៈ | អ្នកទទួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|---|---|
| រៀបចំក្រុមល្បាត ១ក្រុមមាន សមាជិក៥នាក់ | មករា ២០១៨ | មករា ២០១៨ | ក្រដាស ហ្វឺត អាហារសម្រន់ | អាជ្ញាធរឃុំ គណៈកម្មការសហគមន៍ | ថវិកាស្នើសុំផលផល និងអង្គការដៃគូរ |
| ចុះល្បាត៥ដងក្នុង ១ខែ | ២០១៨ | ២០២០ | ទូក អាវភ្លៀង ពិល អាយកូម សាំង អាហារ ថ្នាំពេទ្យ | ប្រធានក្រុមល្បាត | ថវិកាស្នើសុំផលផល និងអង្គការដៃគូរ |

គ.២.១៣ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូល | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | គណៈកម្មការចុះប្រមូលប្រាក់ពីសមាជិក | ២០១៨ | ២០២០ | ៣០០០០០រៀល | សមាជិកសហគមន៍ |
| ភាគទានប្រចាំឆ្នាំ | គណៈកម្មការចុះប្រមូលប្រាក់ពីសមាជិក | ២០១៨ | ២០២០ | ៣៥០,០០០រៀល | ប្រមូល ១ឆ្នាំម្តង |
| ជំនួយសប្បុរសជន និងអង្គការនានា | -សរសេរគម្រោងស្នើសុំ<br>-ផ្សព្វផ្សាយអោយគេដឹង<br>-ធ្វើហិបប្រាក់ភាគទានទ្រទ្រង់សហគមន៍នេសាទ | ២០១៨ | ២០២០ | ២០០០ដុល្លារ | អង្គការ និងរដ្ឋាភិបាល |
| បដិភាគរបស់រដ្ឋាភិបាល ឃុំសង្កាត់ | -បញ្ចូលផែនការអភិវឌ្ឍន៍សហគមន៍ ទៅនឹងផែនការអភិវឌ្ឍន៍ឃុំ<br>-ស្នើសុំប្រាក់បដិភាគពីឃុំដើម្បីអនុវត្តន៍ ផែនការសហគមន៍ | ២០១៨ | ២០២០ | ១៥០០ដុល្លារ | ទទួលពីឃុំ តាមរយៈ បន្ស៊ីផែនការ |
| ចំណូលស្របច្បាប់ផ្សេងៗទៀត | -ប្រាក់ភាគទានពីប្រជានេសាទ ដែលធ្វើការនេសាទក្នុងដែននេសាទរបស់សហគមន៍<br>-ការធ្វើការនេសាទជាសមូហភាព | ២០១៨ | ២០២០ | ៣០០០ដុល្លា | |

### ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជុំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- គៀងគរអោយមានការការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានទប់ស្កាត់ការការហូរចូលអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ឃុំត្នោតជុំ រយៈពេល (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | -ប្រជុំផ្សព្វផ្សាយស្តីពីការប្រើប្រាស់ឧបករណ៍នេសាទនៅតាមព្រៃក ត្រពាំង និងអូរក្នុងកន្លែងនេសាទសហគមន៍នេសាទ | - អ្នកនេសាទនឹងយល់ដឹងអំពីប្រភេទ ទំហំ ប្រវែងឧបករណ៍នេសាទដែលអនុញ្ញាតអោយប្រើប្រាស់ក្នុងកន្លែងនេសាទសហគមន៍នេសាទ | ៦០០ ដុល្លារ | - សប្បុរសជន<br>- បដិភាគសហគមន៍<br>- អង្គការ | ៧/២០១៧ | ១២/២០១៩ | |
| ២. ផែនការកែលម្អដែននេសាទ | -ទំនប់ព្រៃកក្របីខ្វក(៤០ម×៤០ម) លើកទំនប់ស្ទាក់ទឹក ស្នើសុំអាជ្ញាធរដែនដី និងការិយាល័យជលផលខេត្ត | -ដែននេសាទ និងបានជ្រៅ និងបានជ្រៅល្អ មិនរីងនៅរដូវប្រាំង គុណភាពទឹកល្អ<br>-ព្រៃលិចទឹកបានប្រសើឡើងវិញ ត្រី និងសត្វទឹកសំបូរ<br>-មានការគាំទ្រពីរដ្ឋាភិបាល និងអង្គការនានា | ៥០០០ ដុល្លា | - សប្បុរសជន<br>- បដិភាគសហគមន៍<br>អង្គការ | ៤/២០១៨ | ៥/២០១៨ | |
| ៣. ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -កំណត់កន្លែងអភិរក្ស ព្រៃលិចទឹក<br>-កំណត់ព្រំប្រទល់កន្លែងអភិរក្ស ត្រីពូជ បោះបង្គោល ដាក់ស្លាកសញ្ញាហាមឃាត់<br>-ដាក់លូ និងគល់ឈើ ជាជំរកត្រីសិប្បនិម្មិត លែងកូនត្រី<br>-ផ្សព្វផ្សាយសារៈប្រយោជន៍កន្លែងអភិរក្ស<br>-ដាំព្រៃលិចទឹក<br>-រៀបចំក្រុម ចុះល្បាតជាប្រចាំ | -មានស្លាកសញ្ញាកន្លែងអភិរក្ស ត្រីមេពូជ និងព្រៃលិចទឹក<br>-មានបង្គោលចំនួន ៤កន្លែង និងលូស៊ីម៉ងចំនួន ២០លូ និងគល់ឈើសម្រាប់ដាក់ក្នុងកន្លែងអភិរក្សត្រីមេពូជ<br>-មានបង្គោលសម្រាប់បោះក្នុងកន្លែងអភិរក្សអភិរក្សព្រៃលិចទឹកជម្រកសំរាប់ត្រីពងកូន និងបន្តពូជ | ២០០០ ដុល្លារ | - សប្បុរសជន<br>- បដិភាគសហគមន៍<br>- អង្គការ | ៧/២០១៧ | ១២/២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤. ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | - រៀបចំក្រុមការងារ និងចាត់ចែងរកមធ្យោបាយបោះបង្គោលសហគមន៍ ០៤<br>- សហការជាមួយក្រុមបច្ចេកទេសផែនទី និងអ្នកសម្របសម្រួលដើម្បីបោះបង្គោលសហគមន៍អោយចំទៅតាមចំណុចដែលមាននិយាមកាត្រឹមត្រូវនៅលើផែនទីសហគមន៍ និងផ្សព្វផ្សាយពីព្រំប្រទល់សហគមន៍ជាសាធារណៈធ្វើផែនការចុះបោះបង្គោល | - បង្គោលចំនួន ០៤ ដើម នឹងត្រូវបានគេបោះជាព្រំប្រទល់សហគមន៍<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់សហគមន៍<br>- កាត់បន្ថយបទល្មើសនេសាទនៅកន្លែងនេសាទសហគមន៍ និងគ្រប់គ្រងកន្លែងនេសាទបានល្អ | ចំណាយសរុប ៤០០ ដុល្លារ | - សប្បុរសជន<br>- បដិភាគសហគមន៍<br>- អង្គការ | ៨/២០១៧ | ៨/២០១៧ | |
| ៥. ផែនការគ្រប់គ្រងព្រៃលិចទឹក | - ធ្វើថ្នាលផ្សាំកូនដើមរាំង និងកូនសណ្ដាន់ រំដេញ<br>- រៀបចំកន្លែងដែលត្រូវដាំកូនដើមរាំង និងផ្ដោល<br>- រៀបចំដាំដើមឈើចំនួន ២៥០០០ ដើម | - បានបណ្ដុះ និងដាំកូនដើមរាំង និងកូនសណ្ដាន់ រំដេញចំនួន ២៥០០០ ដើម | ៣០០០ ដុល្លារ | - សប្បុរសជន<br>- បដិភាគសហគមន៍<br>- អង្គការ | ០៣/២០១៨ | ០៣/២០១៩ | |
| ៦. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - បង្កើតក្រុមចិញ្ចឹមត្រីប្រា និងត្រីអណ្ដែង<br>- ដឹកនាំ និងចូលរួមវគ្គបណ្ដុះបណ្ដាលអំពីបច្ចេកទេសចិញ្ចឹមត្រីប្រា និងត្រីអណ្ដែង | - ក្រុមចិញ្ចឹមត្រីប្រា និងត្រីអណ្ដែងនឹងត្រូវបានបង្កើត<br>- សហគមន៍នេសាទនឹងមានចំណេះដឹងអំពីការចិញ្ចឹមត្រីប្រា និងត្រី<br>អណ្ដែង | ១០០០ ដុល្លារ | បដិភាគរបស់សហគមន៍នេសាទ និងអង្គការ | ០១/<br>២០១៧ | ០១/២០១៩ | |
| ៧. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | - ដាំបន្លែ ចិញ្ចឹមមាន់ ជ្រូក<br>- បណ្ដុះបណ្ដាលបច្ចេកទេស<br>- ចុះពិនិត្យពិនិត្យ តាមដាន | - សមាជិកសហគមន៍ប្រមាណ ៦០%នឹងទទួលបានបច្ចេកទេស ដាំបន្លែ ចិញ្ចឹមមាន់ | ចំណាយសរុបប្រមាណ២,០០០,០០០ រៀលក្នុង | បដិភាគរបស់សហគមន៍នេសាទ និង | ២០១៧ | ២០១៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | និងកែច្នៃផលនេសាទ និង ជំនាញវិជ្ជាជីវៈ<br>- កាត់បន្ថយការធ្វើនេសាទ<br>- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍<br>- បង្កើនមុខរបរដល់សមាជិក | ១ឆ្នាំ | អង្គការ | | | |
| ៨. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ | - រៀបចំពង្រឹងក្រុមសន្សំ និងប្រាក់កម្ចី និងអនុវត្តដំណើរការធ្វើឥណទាន<br>- ពង្រឹងបណ្តាញសហគមន៍នេសាទ និងបណ្តុះបណ្តាល<br>- រៀបចំក្រុមគំរូដើម្បីអនុវត្តន៍កម្មវិធីទឹកស្អាត សុខភាព អនាម័យ និងបរិស្ថាននៅក្នុងសហគមន៍។ | - សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃក្រុមសន្សំ<br>- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍<br>- អាចទទួលបានព័ត៌មានឆាប់រហ័ស និងអាចពង្រឹងសាមគ្គីភាព<br>- សមាជិកសហគមន៍នឹងមានសុខភាពល្អ កាត់បន្ថយភាពក្រីក្រ | ២,០០០,០០០រៀល ក្នុង ១ឆ្នាំ | បដិភាគរបស់សហគមន៍នេសាទ និង អង្គការ | ២០១៧ | ២០១៩ | |
| ៩. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | - បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ របៀបទុកដាក់ឯកសារ របៀបដោះស្រាយទំនាស់ និងរបៀបសរសេរគម្រោងស្នើសុំថវិកា<br>- ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | - គណៈកម្មការសហគមន៍មានសមត្ថភាពគ្រប់គ្រាន់លើការគ្រប់គ្រង និងស្វែងរកថវិកាតាមរយៈសរសេរគម្រោងស្នើសុំ<br>- គណៈកម្មការសហគមន៍នឹងទទួលបានចំណេះដឹង ឬបទពិសោធន៍ថ្មីៗតាមរយៈទស្សនៈកិច្ច។ | ចំណាយប្រមាណ ៦០០,០០០រៀល លើការបណ្តុះបណ្តាល ៦០០,០០០រៀល លើទស្សនៈកិច្ចសិក្សាក្នុង ១ឆ្នាំ។ | បដិភាគរបស់សហគមន៍នេសាទ និង អង្គការ | ២០១៧ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩.ផែនការផ្សព្វផ្សាយ បណ្តុះបណ្តាល បង្កើន ការយល់ដឹង | **ការផ្សព្វផ្សាយ**<br>- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ<br>- ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ<br>- ច្បាប់ជលផល<br>- ការគ្រប់គ្រងព្រៃលិចទឹក និងសារៈប្រយោជន៍របស់វា ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុល<br>-ការគ្រប់គ្រងកន្លែងអភិរក្ស<br>- គោលការណ៍បង្កើតក្រុមសន្សំ និងការធ្វើឥណទាន<br>**ការបណ្តុះបណ្តាលៈ**<br>- ការដាំព្រៃលិចទឹក<br>- របៀបដំណើរការក្រុមសន្សំ<br>- ការចិញ្ចឹមត្រី<br>- ការធ្វើកសិកម្មចម្រុះ<br>- ការដោះស្រាយទំនាស់<br>- ការងាររដ្ឋបាល<br>- ការគ្រប់គ្រងថវិកា<br>- ជំងឺសមុខបរទ្រទ្រង់ជីវភាព<br>- ការប្រើប្រាស់ថវិកាសហគមន៍អោយបានសមស្រប | - សមាជិកសហគមន៍ប្រមាណ ៦០%បានយល់ដឹងពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ច្បាប់ជលផល ផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំពុលកសិកម្ម<br>- ប្រជាពលរដ្ឋស្គាល់ច្បាស់ពីព្រំប្រទល់ដែននេសាទសហគមន៍ និងកន្លែងអភិរក្សរបស់សហគមន៍<br>- សមាជិកសហគមន៍ ៣០%អាចចេះបច្ចេកទេសដាំព្រៃលិចទឹក ការកែច្នៃផលនេសាទ<br>- ចេះដោះស្រាយទំនាស់ ចេះទុកដាក់ឯកសារលិខិតស្នាម រដ្ឋបាល ចេះសរសេរកំណត់ហេតុរបាយការណ៍ ចេះគ្រប់គ្រង និងប្រើប្រាស់ថវិការបស់សហគមន៍បានសមស្រប និងមានតម្លាភាព។<br>- យល់ដឹងពីតួនាទីស្ត្រី និងចេះវិភាគមុខរបរចិញ្ចឹមជីវិត។ | ចំណាយប្រមាណ ១០០០ ដុល្លារ | បដិភាគរបស់សហគមន៍នេសាទ និង អង្គការ, សប្បុរសជន | ២០១៧ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩. ពង្រឹងការល្បាត និងឃ្លាំមើលបទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍ | - រៀបចំក្រុម និងធ្វើផែនការល្បាត<br>- រៀបចំវេនយាម ល្បាត សម្ភារៈ និងមធ្យោបាយល្បាត<br>- រៀបចំពង្រឹងបណ្តាញសហគមន៍<br>-បណ្តុះបណ្តាលពីការល្បាត និងតួនាទីបណ្តាញ<br>ទស្សនៈកិច្ចសិក្សា | -បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍ និងកាត់បន្ថយបាន ៨០%<br>-កាត់បន្ថយបាននូវការទំនាស់នេសាទក្នុងដែននេសាទសហគមន៍<br>-ទទួលបានពត៌មានឆាប់រហ័ស និងមានសហការល្អ<br>-ស្វែងរកបទពិសោធន៍ល្អ | - ចំណាយប្រមាណ ១,០០០,០០០ រៀលលើល្បាតក្នុង ១ឆ្នាំ<br>- ចំណាយប្រមាណ ៥,០០០,០០០រៀលលើការសាងសង់ផាង<br>- ចំណាយប្រមាណ ៣,២០០,០០០រៀលលើការទិញទូក និងសម្ភារៈល្បាត។ | បដិភាគរបស់សហគមន៍នេសាទ និងអង្គការ, សប្បុរសជន | ២០១៧ | ២០២០ | |
| ១០. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | - ការប្រមូលប្រាក់សមាជិកភាព និងប្រាក់ភាគទានប្រចាំឆ្នាំ<br>- សរសេរគម្រោងស្នើសុំ<br>- ចូលរួមយ៉ាងសកម្មក្នុងការបង្ក្រាបបទល្មើសផលផលជាមួយសមត្ថកិច្ចជំនាញ ដើម្បីទទួលបានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ទ្រទ្រង់សហគមន៍<br>- ចូលរួមបន្សុីផែនការសហគមន៍ជាមួយផែនការអភិវឌ្ឍន៍<br>- ផ្សព្វផ្សាយអោយគេដឹងពីសហគមន៍ទាក់ទាញ និងស្វែងរកថវិកាតាមរយៈការប្រើប្រាស់ហិបវិភាគទាន។ | - សហគមន៍នឹងទទួលបានថវិកាមួយចំនួនដើម្បីអភិវឌ្ឍន៍សហគមន៍<br>- ក្រុមប្រឹក្សាឃុំនឹងទទួលយកការគាំទ្រ និងការអនុវត្តន៍គម្រោង<br>- មានការគាំទ្រពីសប្បុរសជន និងអង្គការនានា ផ្តល់ថវិកាដើម្បីអនុវត្តន៍ផែនការសហគមន៍។ | - ចំណាយថវិកាប្រមាណ ៧០ ដុល្លារក្នុង ១ឆ្នាំ | បដិភាគរបស់សហគមន៍នេសាទ | ២០១៧ | ២០២០ | |

សូមគោរពជូន

**លោកមេឃុំឡោតជុំ**

" ដើម្បីជូនពិនិត្យនិងសម្រួល "

.......ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧

**ប្រធានគណៈកម្មការសហគមន៍នេសាទឡោតជុំ**

លេខ:០០១/១៨...

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលបារាយណ៍

"ដើម្បីជូនពិនិត្យនិងសម្រួល"

.......ថ្ងៃទី...... ខែ...... ឆ្នាំ២០១៧

**មេឃុំឡោតជុំ**

គង់_លីម

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ

"ដើម្បីជូនពិនិត្យនិងសម្រួល"

.......ថ្ងៃទី...... ខែ...... ឆ្នាំ២០១៨

**នាយសង្កាត់រដ្ឋបាលជលផលបារាយណ៍**

លេខ:......

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

.......ថ្ងៃទី...... ខែ...... ឆ្នាំ២០១៨

**នាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ**

លេខ :១៦៣.....

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ខេត្តកំពង់ធំ-

" ដើម្បីជូនពិនិត្យនិងសម្រួល "

.......ថ្ងៃទី...... ខែ...... ឆ្នាំ២០១៨

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប៉ែន_វណ្ណារិទ្ធ**

លេខ :...... 

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ "

........ ថ្ងៃទី...... ខែ...... ឆ្នាំ២០១៨

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**-ខេត្តកំពង់ធំ-**

**ជីវ វណ្ណធី**

លេខ:៣១១៤.....ជជ

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**